**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ២០៤៧ ប្រក.

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគម

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះលេខ០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា

## សម្រេច

**ប្រការ ១ .-**

ត្រូវបានចុះឈ្មោះ **សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ១៦ ផ្លូវលេខ៤៣០ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ប្រការ ២ .-**

**សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣ .-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៨កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២០

ជ. រដ្ឋមន្ត្រី
**រដ្ឋលេខាធិការ**

ប៊ុន-ហ៊ុក

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ២០៤៧ ប្រក.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
# ស្ដីពី
# ការចុះឈ្មោះក្នុងបញ្ជីសមាគម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះលេខ០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់សមាគមអ្នកផ្ដល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា

## សម្រេច

**ប្រការ ១** .-

ត្រូវបានចុះឈ្មោះ ***សមាគមអ្នកផ្ដល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា*** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្ដាលតាំងនៅផ្ទះលេខ១៦ ផ្លូវលេខ៤៣០ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ប្រការ ២** .-

***សមាគមអ្នកផ្ដល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា*** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** .-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...[illegible]...ខែ...[illegible]......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី...[illegible]... ខែ...[illegible]......ឆ្នាំ២០២០

ឧ - រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុន-ហ៊ុន

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២០៤៧ ប្រក.

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគម

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះលេខ០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា

### សម្រេច

**ប្រការ ១** .-

ត្រូវបានចុះឈ្មោះ **សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ១៦ ផ្លូវលេខ៤៣០ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ប្រការ ២** .-

**សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** .-

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហ.១០កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០២០

ជ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុន-ហុន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៣ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ

របស់

# សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា

Cambodia Green Building Council

## ជំពូកទី ១
## គោលបំណង និងគោលដៅ

**ប្រការ ១._ អំពីគោលបំណង**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានគោលបំណងសំខាន់គឺ៖

- ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។
- ចូលរួមលើកស្ទួយវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងសំណង់នៅកម្ពុជា
- ជំរុញឧស្សាហកម្មសំណង់ នៅកម្ពុជាឆ្ពោះទៅរកនិទន្តភាពបរិស្ថាន និងផ្តោតលើគុណភាព
- សហការយ៉ាងជិតស្និតបំផុតជាមួយដៃគូថ្នាក់ជាតិ និងអន្តរជាតិ សម្រាប់ឲ្យវិស័យសំណង់មានភាពល្អប្រសើរ ។
- ធ្វើការផ្សព្វផ្សាយអំពីការច្នៃប្រឌិត និងភាពជាអ្នកដឹកនាំក្នុងការរចនាអគារ និងការថែរក្សាសំណង់បៃតង ។
- រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

## ជំពូកទី ២
## ការកំណត់ឈ្មោះ ទីស្នាក់ការ អត្តសញ្ញាណ សញ្ញាសម្គាល់ និងត្រា

**ប្រការ ២._ អំពីការកំណត់ឈ្មោះ**

សមាគមនេះមានឈ្មោះជាភាសាខ្មែរថា (**សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា**) សរសេរអក្សរកាត់ថា (**សអសអបក**) និងមានឈ្មោះជាភាសាអង់គ្លេសថា Cambodia Green Building Council (CamGBC)។

**ប្រការ ៣._ អំពីទីស្នាក់ការ**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានទីស្នាក់ការណ្តាលតាំងនៅរាជធានីភ្នំពេញ។ សមាគមអាចបង្កើតឲ្យមានទីស្នាក់ការសាខារបស់ខ្លួននៅតាមបណ្តាខេត្តនានា ទូទាំងព្រះរាជាណាចក្រកម្ពុជា ទៅតាមតម្រូវការចាំបាច់របស់សមាគម។

ទីស្នាក់ការកណ្តាល និងទីស្នាក់ការសាខានៅតាមបណ្តាខេត្តនានា អាចត្រូវផ្លាស់ប្តូរបាននៅក្នុងករណីចាំបាច់ដោយត្រូវអនុវត្តទៅតាមសេចក្តីសម្រេចចិត្តក្នុងសំឡេង ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ។

លក្ខន្តិកៈ
ស.អ

**ប្រការ ៤.- អត្តសញ្ញាណ**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា គឺជាសមាគមមិនស្វែងរកកម្រៃជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ និងមិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះរួមទាំងមិនផ្តល់មធ្យោបាយជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឡើយ។

**ប្រការ ៥.- អំពីសញ្ញាសម្គាល់**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានសញ្ញាសម្គាល់ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ ដែលភ្ជាប់មកជាមួយលក្ខន្តិកៈនេះ។

**ប្រការ ៦.- អំពីត្រា**

ត្រារបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានសណ្ឋានដូចសញ្ញាសម្គាល់របស់សមាគម ហើយត្រារបស់សមាគមមានទំហំ ៣៤ម.ម ដោយកំណត់ប្រើនូវប្រភេទទឹកត្រាពណ៌ខៀវ។

## ជំពូកទី ៣

## សមាជិកភាព ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព

**ប្រការ ៧.- អំពីសមាជិកភាព**

ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ មានសិទ្ធិសុំចូលជាសមាជិករបស់សមាគមបាន។ រាល់សមាជិករបស់សមាគមទាំងអស់ត្រូវគោរព និងអនុវត្តទៅតាមច្បាប់នានា លិខិតបទដ្ឋានគតិយុត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងរាល់សេចក្តីសម្រេចរបស់សមាគម។

**ប្រការ ៨.- អំពីសមាជិករបស់សមាគម**

សមាជិករបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា រួមមាន៖

១- សមាជិកស្ថាបនិក គឺជាអ្នកដែលបានផ្តួចផ្តើមបង្កើតសមាគមនេះឡើង

២- សមាជិកកិត្តិយស គឺជាអ្នកដែលបានចូលរួមផ្តល់ជាគំនិតយោបល់ ជួយជ្រោមជ្រែងដល់សមាគមនេះ ដើម្បីបានបង្កើត និងដំណើរការដោយមិនគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន

៣- សមាជិកសកម្ម គឺជាអ្នកចូលរួមអនុវត្តក្នុងសកម្មភាពរបស់សមាគម ក្នុងនោះមានដូចជាការពិភាក្សា ផ្តល់នូវបទពិសោធន៍រាល់កិច្ចការ និងសំណូមពរផ្សេងៗ របស់សមាគម

៤- សមាជិកគាំទ្រ គឺជាអ្នកដែលផ្តល់នូវប្រភពធនធាន មានដូចជា សម្ភារ ថវិកា និងស្មារតី នៃការគាំទ្រ ឲ្យសមាគមមានដំណើរការស្របតាមគោលបំណងរបស់ខ្លួន ។

**ប្រការ ៩.- អំពីការជ្រើសរើសបុគ្គលិក**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា អាចជ្រើសរើសបុគ្គលិកឲ្យចូលបម្រើការងារទៅតាមការចាំបាច់របស់សមាគម នឹងត្រូវអនុវត្តតាមរយៈការប្រឡង ឬការធ្វើតេស្ត និងត្រូវចុះកិច្ចសន្យាការងារដោយអនុលោមទៅតាមច្បាប់ស្តីពីការងាររបស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០.- អំពីតួនាទី ភារកិច្ចរបស់សមាជិក និងបុគ្គលិក**

គ្រប់សមាជិក និងបុគ្គលិករបស់សមាគមត្រូវបំពេញការងារតាមតួនាទី ភារកិច្ចរបស់ខ្លួនទៅតាមការកំណត់ដូចមានចែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់សមាគម។

គ្រប់សមាជិកនិងបុគ្គលិករបស់សមាគម មិនត្រូវបានអនុញ្ញាតឲ្យយកឈ្មោះរបស់សមាគមទៅបម្រើនៅក្នុងផលប្រយោជន៍បុគ្គល ឬបម្រើឲ្យផលប្រយោជន៍គណបក្សនយោបាយណាមួយឡើយ។

ស.អ

**ប្រការ ១១.- អំពីការបាត់បង់សមាជិកភាព និងបុគ្គលិកភាព**

ចំពោះការបាត់បង់សមាជិកភាព និងបុគ្គលិកភាពរបស់សមាគម ត្រូវបានកំណត់ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ទទួលមរណភាព
- ចប់កិច្ចសន្យាការងារ
- បានដាក់ពាក្យសុំលាឈប់ដោយផ្ទាល់ជាលាយលក្ខណ៍អក្សរ ដោយត្រូវដាក់ជូនទៅគណៈកម្មការប្រតិបត្តិឲ្យបាន១៥ (ដប់ប្រាំ)ថ្ងៃ មុននឹងលាឈប់ពីការងារ
- ត្រូវបានបញ្ឈប់ដោយសេចក្ដីសម្រេចរបស់គណៈកម្មការប្រតិបត្តិតាមសំឡេង ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ ក្រោយពីទទួលបានការណែនាំពីប្រធានសមាគមចំនួន ២(ពីរ) លើករួចមក ហើយនៅតែពុំកែខ្លួនដោយមូលហេតុមិនគោរពទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្ដីសម្រេចនានារបស់សមាគម
- មានជាប់ពិរុទ្ធក្នុងបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលមានសាលក្រម ឬសាលដីកាស្ថាពរដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា
- មានជំងឺវិបល្លាសស្មារតី ឬវិកលចរិត ដែលមានលិខិតបញ្ជាក់ចេញដោយមន្ទីរពេទ្យស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១២.- អំពីការបញ្ឈប់ និងការជ្រើសរើស**

ក្នុងករណីការបញ្ឈប់សមាជិក ឬបុគ្គលិកណាមួយនោះ គណៈកម្មការប្រតិបត្តិត្រូវប្រជុំគ្នាដើម្បីជ្រើសរើសអ្នកថ្មីមកជំនួស។

## <u>ជំពូកទី ៤</u>

## រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

**ប្រការ ១៣.- អំពីរចនាសម្ព័ន្ធ**

សមាគមអ្នកផ្ដល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖

- សន្និបាត គឺជាស្ថាប័នដឹកនាំកំពូលរបស់សមាគម សន្និបាតរួមមាន សន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មការប្រតិបត្តិ។

**ប្រការ ១៤.- អំពីសន្និបាតសាមញ្ញ**

សន្និបាតសាមញ្ញ ត្រូវរៀបចំឡើងរៀងរាល់មួយឆ្នាំម្ដង ដោយមានការចូលរួមពីសមាជិកទាំងអស់របស់សមាគម តាមការអញ្ជើញរបស់ប្រធានសមាគម។ សមាជិកកិត្តិយសមានសិទ្ធិចូលរួមក្នុងអង្គសន្និបាតបាន ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ រីឯនីតិវិធី របៀបវារៈ ទីកន្លែង និងពេលវេលាជាភារកិច្ចរបស់ រដ្ឋបាល។

**សន្និបាតសាមញ្ញមានភារកិច្ច**

- បោះឆ្នោតជ្រើសរើស សមាជិកគណៈកម្មការប្រតិបត្តិ នៅពេលចប់អាណត្តិ
- ពិនិត្យវាយតម្លៃលើរបាយការណ៍ស្ដីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុដែលបានអនុវត្តកន្លងមក
- ពិនិត្យ និងអនុម័តលើទិសដៅ គោលបំណង និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬលក្ខខណ្ឌការងារ
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀត ដែលស្នើឡើងដោយគណៈកម្មការប្រតិបត្តិ។

**ប្រការ ១៥.- អំពីសន្និបាតវិសាមញ្ញ**

ក្នុងករណីចាំបាច់ ឬពិសេស សមាគមអាចរៀបចំសន្និបាតវិសាមញ្ញបាន ដោយមិនកំណត់ពេលវេលាតាមការអញ្ជើញរបស់ប្រធានសមាគម ឬតាមសំណើសុំ ២/៣ (ពីរភាគបី) នៃចំនួនសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម។

**សន្និបាតវិសាមញ្ញមានភារកិច្ច**

- ពិនិត្យ ពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈក្នុងករណីចាំបាច់
- ពិនិត្យ សម្រេចលើការផ្លាស់ប្តូរប្រធានសមាគម
- ពិនិត្យ និងអនុម័តលើការរំលាយសមាគមនិងការចាត់ចែងទ្រព្យសម្បត្តិរបស់សមាគម
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀត ដែលចាំបាច់នៅក្នុងសមាគម។

**ប្រការ ១៦.– អំពីលក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គសន្និបាតទាំងពីរប្រភេទមានតម្លៃគតិយុត្តបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ លើកូរ៉ុមចូលរួមក្នុងសន្និបាតយ៉ាងហោចណាស់ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ។

ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានអង្គសន្និបាតមានឧត្តមានុភាព។ ប្រធានអង្គសន្និបាតអាចជាប្រធានសមាគម ឬបុគ្គលដែលមានឯករាជ្យភាពតាមការជ្រើសរើសរបស់អង្គសន្និបាត។

**ប្រការ ១៧.– អំពីគណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិ មានសមាជិកយ៉ាងតិច ០៣ (បី) រូប និងមានអាណត្តិ ០៥(ប្រាំ) ឆ្នាំ។ នៅពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកគណៈកម្មការប្រតិបត្តិចាស់មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតជាថ្មីទៀតបាន។

**ប្រការ ១៨.– អំពីសមាជិកគណៈកម្មការប្រតិបត្តិ**

សមាជិកគណៈកម្មការប្រតិបត្តិ ជ្រើសតាំងឡើងតាមការបោះឆ្នោត ដោយសំឡេងគាំទ្រ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម និងមានសមាជិកយ៉ាងតិចចំនួន ០៣( បី ) រូបដូចខាងក្រោម៖

- ប្រធាន ០១ រូប
- រដ្ឋបាល/ហេរញ្ញិក ០១ រូប
- ប្រធានកម្មវិធី ០១ រូប

**ប្រការ ១៩.– អំពីប្រធានគណៈកម្មការប្រតិបត្តិ**

ប្រធានគណៈកម្មការប្រតិបត្តិ គឺជាប្រធានសមាគម និងជាតំណាងស្របច្បាប់របស់សមាគមដែលមានតួនាទីជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវនូវគ្រប់សកម្មភាពរបស់សមាគម។

**ប្រការ ២០.– អំពីរដ្ឋបាល/ហេរញ្ញិក**

មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល ទ្រព្យសម្បត្តិ សារពើភណ្ឌ
- រៀបចំលិខិតបទដ្ឋាន និងរក្សាតម្កល់ទុកឯកសារ
- គ្រប់គ្រងការងារបុគ្គលិក
- ធ្វើកំណត់ហេតុអង្គប្រជុំនានា និងអង្គសន្និបាត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ
- គ្រប់គ្រង និងត្រួតពិនិត្យរាល់ចំណូល ចំណាយរបស់សមាគម
- ធ្វើគម្រោងថវិកាប្រចាំឆ្នាំ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនប្រធានសមាគម ដើម្បីដាក់ជូនទៅគណៈ-កម្មការប្រតិបត្តិពិនិត្យ និងសម្រេច។

**ប្រការ ២១.– អំពីប្រធានកម្មវិធី** មានតួនាទីគ្រប់គ្រងគ្រប់កម្មវិធីទាំងអស់របស់សមាគម។

**ប្រការ ២២.– អំពីកិច្ចប្រជុំគណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិត្រូវជួបប្រជុំគ្នា ០១ដង ក្នុងមួយខែ តាមការអញ្ជើញរបស់ប្រធានសមាគម និងអាចប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានសមាគម ឬ២/៣(ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ។

**ប្រការ ២៣._ អំពីលក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការប្រតិបត្តិទាំងពីរប្រភេទមានតម្លៃគតិយុត្តបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ លើកូរ៉ុមចូលរួមក្នុងអង្គប្រជុំយ៉ាងហោចណាស់ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ។

**ប្រការ ២៣._ អំពីទីប្រឹក្សា និងក្រុមប្រឹក្សាភិបាល**

សមាគមមានក្រុមប្រឹក្សាភិបាល ដើម្បីជួយក្នុងការផ្តល់ជាគំនិតយោបល់ក្នុងគោលបំណងសម្រួលដល់ការងាររបស់សមាគមឲ្យកាន់តែមានភាពរីកចម្រើនប្រសើរឡើង។

ក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងឡើងដោយគណៈកម្មការប្រតិបត្តិ។

## ជំពូកទី ៥

## វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬវិសោធនកម្មលក្ខន្តិកៈ

**ប្រការ ២៤._ អំពីវិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា អាចប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់បានតាមសំណើសុំរបស់ប្រធានសមាគម ឬតាមសំណូមពរ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម។ ការអនុម័តលើរាល់ការសម្រេច នៃការប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់របស់សមាគម គឺជាសមត្ថកិច្ចរបស់សន្និបាត។

**ប្រការ ២៥._ អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈ**

លក្ខន្តិកៈរបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា អាចធ្វើវិសោធនកម្មបានតាមសំណើសុំរបស់ប្រធានសមាគម ឬតាមសំណូមពរ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម។ ការអនុម័តលើរាល់ការសម្រេច នៃការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា គឺជាសមត្ថកិច្ចរបស់សន្និបាត។

## ជំពូកទី ៦

## ប្រភពធនធាន ទ្រព្យសម្បត្តិ និងការគ្រប់គ្រង

**ប្រការ ២៦._ អំពីប្រភពធនធាន ទ្រព្យសម្បត្តិ**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានប្រភពមូលនិធិបានមកពី៖

- ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក
- ធនធាន ទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត។

**ប្រការ ២៧._ អំពីការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ**

រាល់ចំណូលទាំងអស់របស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា ត្រូវគ្រប់គ្រងដោយហេរញ្ញិករបស់សមាគម ដោយមានការចុះហត្ថលេខាយល់ព្រមពីប្រធានសមាគម។ ចំណូលជាសាច់ប្រាក់ ឬមូលប្បទានប័ត្រទាំងអស់ត្រូវបញ្ចូលទៅក្នុងគណនីធនាគារស្របច្បាប់ណាមួយរបស់សមាគម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅតាមការសម្រេចរបស់គណៈកម្មការប្រតិបត្តិ។

ថវិកាអាចរក្សាទុកមួយចំនួននៅក្នុងបេឡារបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា សម្រាប់ប្រើប្រាស់ជាការចាំបាច់ក្នុងសមាគមតាមការកំណត់របស់គណៈកម្មការប្រតិបត្តិ។

រាល់ការដកសាច់ប្រាក់ ឬមូលប្បទានប័ត្រពីធនាគារ ត្រូវមានការចុះហត្ថលេខារបស់ហេរញ្ញិក និងប្រធានសមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា ឬអាចផ្ទេរសិទ្ធិទៅឱ្យរូបវន្តបុគ្គលដែលជាសមាជិកគណៈកម្មការប្រតិបត្តិតាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីសាមីខ្លួនដែលមានសិទ្ធិ។

## ជំពូកទី ៧

## ការផ្អាកសកម្មភាព ការរំលាយសមាគម ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ

**ប្រការ ២៨._ អំពីការផ្អាកសកម្មភាពសមាគម**

មានតែសន្និបាតតែមួយគត់ដែលអាចសម្រេចក្នុងការផ្អាកសកម្មភាព សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា នេះបាន។ មុនពេលសមាគមត្រូវបានផ្អាកសកម្មភាព សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីគ្រប់គ្រងនូវទ្រព្យសម្បត្តិរបស់សមាគម។

**ប្រការ ២៩._ អំពីការរំលាយសមាគម**

មានតែសន្និបាតតែមួយគត់ដែលអាចសម្រេចក្នុងការរំលាយសមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា នេះបាន។ មុនពេលសមាគមត្រូវបានរំលាយ សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជីរបស់សមាគម។

**ប្រការ ៣០._ អំពីការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលរំលាយសមាគម**

រាល់ទ្រព្យសម្បត្តិរបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា ដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់សមាគមរួច ត្រូវចាត់ចែងទៅតាមការសម្រេចរបស់គណៈកម្មការប្រតិបត្តិ ឬប្រគល់ជូនសមាគមជាតិកាកបាទក្រហមកម្ពុជា។ សមាជិក និងបុគ្គលិកសមាគមទាំងអស់ក៏ត្រូវបានរំសាយផងដែរនៅពេលដែលសមាគមត្រូវបានរំលាយ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**ប្រការ ៣៣._**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា ដែលមានខ្លឹមសារផ្ទុយពីលក្ខន្តិកៈនេះនឹងត្រូវទុកជានិរាករណ៍។

**ប្រការ ៣៤._**

សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា ត្រូវធ្វើសកម្មភាពដោយអនុវត្តឱ្យស្របតាមលក្ខន្តិកៈរបស់ខ្លួនដូចដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ ៣៥._**

លក្ខន្តិកៈរបស់សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

បានតម្កល់ទុកលក្ខន្តិកៈ
របស់
សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា
ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស
លេខ ២០៤៧ ប្រ.ក ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០។
រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០
នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ
ប្រធាន

ឈឹម ភាន

(ត្រា: លក្ខន្តិកៈ ស.អ)

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០
ជ.គណៈកម្មការប្រតិបត្តិ
ប្រធាន

ជា លីម៉ុនសៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រចនាសម្ព័ន្ធ
របស់
# សមាគមអ្នកផ្តល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា
Cambodia Green Building Council




រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០
ជ.គណៈកម្មការប្រតិបត្តិ
ប្រធាន

ជា លីម៉ុនសៀង

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធសញ្ញាសម្គាល់ និងត្រា
# របស់សមាគមអ្នកផ្ដល់ប្រឹក្សាសំណង់អគារបៃតងកម្ពុជា

Cambodia Green Building Council

**ក.<u>សញ្ញាសម្គាល់</u>**

**ខ.<u>ត្រា</u>**

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

លក្ខន្តិកៈ
ស.អ

**ជា លីម៉ុនសៀង**